**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**********

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៧ **នាមនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ **តុលាការកំពូល**

**សាលដីកា**

លេខ: ៣៥ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣

ចុះថ្ងៃទី០៩ខែកក្កដាឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ប្រាក់ គីមសាន ជាចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ស៊ិន ឌឹម ជាចៅក្រម

**ក្រឡាបញ្ជី**

លោក សាន សុជាត

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៥"ឈ"ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៧ ចុះ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

**__ចំបទ:__** ឆបោកប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី២២-២៦ ខែវិច្ឆិកា ឆ្នាំ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

-ជនជាប់ចោទឈ្មោះលី ប៊ុនសេង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥០ឆ្នាំ ជាតិវៀតណាម ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ៧២E, ផ្លូវ៣២៨ សង្កាត់ទួលស្វាយព្រៃII ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះលី ទ្វី "ស" ម្តាយឈ្មោះហ្វាង ធីសៀង "ស" ប្រពន្ធឈ្មោះចាន់ ម៉ាលី មានកូន២នាក់ ។ ក្នុងឃុំ ។

-មានមេធាវី លោកសោម ច័ន្ទឌីណា

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះដួង ធីសយ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៦ឆ្នាំ ជាតិវៀតណាម ទីលំនៅសព្វថ្ងៃផ្ទះលេខ៨៩DE₀ ផ្លូវ១០៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។

-មានមេធាវី លោកលឹម វណ្ណា

-តាមពាក្យបណ្តឹងចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ដួង ធីសយ ប្តឹងពីឈ្មោះលី ប៊ុនសេង ពីបទឆបោក តាមរូបភាពកក់ប្រាក់នៃកិច្ចសន្យាសាងសង់ ដោយអាងហេតុថា: ឈ្មោះលី ប៊ុនសេង បានទាក់ទងខ្លួនដើម្បីសាងសង់សំណង់ឧត្តរមានជ័យដោយ បាននាំខ្លួនទៅមើលទីតាំងដើម្បីសាងសង់ហើយបានកក់ប្រាក់ចំនួន១៨.០០០$ នៅថ្ងៃទី២២-១១-២០០១ ព្រមទាំងប្រាក់ដុងចំនួន១៥.០០០.០០០ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ ទៀតផង ។ ក្រោយពី ខ្លួនប្រគល់ប្រាក់អស់ហើយស្រាប់តែឈ្មោះលី ប៊ុនសេង ពុំមានការដ្ឋានឱ្យខ្លួនសាងសង់ឡើយ ហើយ គេបានគេចខ្លួនទៅវៀតណាម ទើបខ្លួនប្តឹងឱ្យឃាត់ខ្លួនឈ្មោះលី ប៊ុនសេង តែម្តងទៅ ។

-បានឃើញដីកាសំរេចលេខ៣៨១ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-បដិសេធពាក្យសុំធានាឱ្យឈ្មោះលី ប៊ុនសេង នៅក្រៅឃុំរបស់ឈ្មោះកែវ សារី និងមេធាវី ណាវ ទ្រី ចោល ។

២-បន្តការឃុំខ្លួនឈ្មោះលី ប៊ុនសេង បន្តទៀតតាមដីកាឃុំខ្លួនលេខ១៤ ចុះថ្ងៃទី០៦-០១-០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ពីបទឆបោកប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពី ថ្ងៃទី២២-២៦ ខែវិច្ឆិកា ឆ្នាំ២០០១ ។

៣-ទុកសិទ្ធិគូភាគីតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៣ របស់លោកណាច ទ្រី មេធាវីការពារជនជាប់ចោទ ប្តឹងមិនសុខចិត្តពីដីកាសំរេចលេខ៣៨១ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៣របស់ ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : រឿងនេះស្ថិតក្នុង ដំណាក់កាលស៊ើបអង្កេតជនជាប់ចោទគ្មានអាស័យដ្ឋានពុំពិតប្រាកដ គប្បីតម្កល់ដីកាឃុំខ្លួនទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៥"ឈ"ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកមេធាវី ណាច ទ្រី ទុកជាត្រឹម ត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាសំរេចលេខ៣៨១ ចុះថ្ងៃទី១៦-០១-២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុង ភ្នំពេញ ទុកជាបានដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារឱ្យជនជាប់ចោទ និង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកណាច ទ្រី មេធាវី ការពារឱ្យជនជាប់ចោទ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០៥"ឈ"ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះលី ប៊ុនសេង (ជាម្ចាស់បណ្តឹង សាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣ របស់មេធាវី លឹម វណ្ណា មេធាវីការពារ អ្នកស្រីដួង ធីសយ (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: មានភស្តុតាងគ្រប់គ្រាន់ លើឈ្មោះលី ប៊ុនសេង ដោយសារបទល្មើសជាបទល្មើសមជ្ឈឹម សូមឱ្យក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះលី ប៊ុនសេង (ជាម្ចាស់បណ្តឹងសាទុក្ខ)តាមរយៈឈ្មោះគីម ហេង ជាអ្នកបកប្រែនៅពេលជំនុំជំរះថា : ខ្ញុំបាទមិនបានឆបោកដួង ធីសយ ទេ ចែដន្យគំរោងសាងសង់ត្រូវបាន អាក់ខានវិញ ខ្ញុំបានសងលុយរំលោះទៅដួង ធីសយ ជាបណ្តើរ។ តែគេចាប់ខ្ញុំបាទបញ្ជូនមកតុលាការតែម្តង ។ សូមតុលាការមេត្តាដោះលែងខ្ញុំបាទផង ។

-បានស្តាប់អំណានសារណាតបឈ្មោះដួង ធីសយ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារលោកសោម ច័ន្ទឌីណា មេធាវីការពារជនជាប់ចោទឈ្មោះលី ប៊ុនសេង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា: កូនក្តីខ្ញុំគ្មានគំនិតឆបោកគេទេ ហើយបានសងទៅ ដួង ធីសយ ចំនួន៨លើកមកហើយ។ កូនក្តីខ្ញុំមានប្រពន្ធកូនមានមុខរបរច្បាស់លាស់មានអាស័យដ្ឋានត្រឹមត្រូវ មិន គេចវេសនៃការសង រឺ ពីនីតិវិធីរបស់តុលាការបានឡើយ។

សូមតុលាការមេត្តាដោះលេងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នសិន ការឃុំខ្លួនបាន៦ខែហើយ។ រងចាំ តុលាការសំរេចដល់អង្គសេចក្តីជាក្រោយ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារលោក លឹម វណ្ណា មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ដួង ធីសយ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ជនជាប់ចោទពិតជាមានគំនិតឆបោក ព្រោះមាន ភស្តុតាងគ្រប់គ្រាន់ ជនជាប់ចោទគ្មានអាស័យដ្ឋានច្បាស់ នៅផ្ទះជួលបង្កការងាយស្រួលដល់ជនជាប់ចោទ ក្នុង ការគេចខ្លួន ព្រោះកន្លងមកទំរាំចាប់ជនជាប់ចោទជាការពិបាកណាស់ ។

ដូច្នេះសូមតុលាការបន្តការឃុំខ្លួនបន្តទៀត ហើយសូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: សូមរក្សាការសន្និដ្ឋានខាងលើទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះណាច ទ្រី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចបដិសេធពាក្យសុំធានាឱ្យជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្ន ដោយអាងហេតុថា ការស៊ើបអង្កេតពុំទាន់មានសភាពជឿនលឿននៅឡើយ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះជនជាប់ចោទនេះត្រូវចោទពីបទមជ្ឈឹមប៉ុណ្ណោះ ហើយអង្គហេតុនៃរឿងនេះ ពុំមានអ្វីស្មុគស្មាញនាំឱ្យពិបាកស៊ើបអង្កេតទេ ។ ម្យ៉ាងទៀតតាមអត្តសញ្ញាណប័ណ្ណលេខ៣៦.៩៤៩១ភព ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៣ តាមលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ និងតាមប័ណ្ណចុះឈ្មោះបោះឆ្នោតចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧ ជនជាប់ចោទពិតជាមានទីលំនៅ និងមុខរបរ នៅក្រុងភ្នំពេញប្រាកដមែន ។

ដូច្នេះការឃុំខ្លួនជនជាប់ចោទពុំមែនជាលក្ខខ័ណ្ឌចាំបាច់ដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឡើយ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៥"ឈ" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគិតច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខ

## ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកណាច ទ្រី ទុកជាត្រឹម

ត្រូវតាមទំរង់ នីងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ០៥"ឈ" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្គាប់ឱ្យដោះលែងឈ្មោះលី ប៊ុនសេង ពីការឃុំខ្លួនជាបណ្តោះអាសន្ន ប្រសិនបើឈ្មោះនេះពុំមានជាប់ឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមច្បាប់តទៅ ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៣ ។